ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ:...... សហវ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ កក្កដា ឆ្នាំ ២០០៩

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់ព័ត៌មានដែលទទួលបានដោយមន្ត្រីគយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១.-**

ព័ត៌មានដែលទទួលបានដោយមន្ត្រីគយនៅក្នុងការគ្រប់គ្រង ឬការអនុវត្តច្បាប់ គយ អាចប្រើប្រាស់បានសម្រាប់តែគោលបំណងដែលមានចែងក្នុងច្បាប់ជាធរមាន ឬ ត្រូវបានអនុញ្ញាតដោយឡែកក្រោមបញ្ញត្តិនានានៃប្រកាសនេះ ។

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

Downloaded from: http://www.khmerlaws.com

ព័ត៌មានដែលទទួលបានដោយមន្ត្រីគយនៅក្នុងការគ្រប់គ្រង ឬការអនុវត្តច្បាប់រួមមាន ៖

- ព័ត៌មានដែលត្រូវបានផ្តល់ជូនរដ្ឋបាលគយ ដោយនីតិបុគ្គល ឬរូបវន្តបុគ្គលពាក់ព័ន្ធនឹងការនាំចេញ ការនាំចូល ការដឹកជញ្ជូន ឬការធ្វើសន្និធិទំនិញ និងពីតំណាងស្របច្បាប់របស់បុគ្គលទាំងនេះ រាប់បញ្ចូលទាំងដើងសារគយ ឬភ្នាក់ងារតំណាងស្របច្បាប់នានា
- ព័ត៌មានដែលត្រូវបានផ្តល់ដោយមន្ត្រីនៃស្ថាប័ន និងអាជ្ញាធរផ្សេងទៀតរបស់រាជរដ្ឋាភិបាល
- ព័ត៌មានដែលត្រូវបានផ្តល់ដោយរដ្ឋបាលគយនិងភ្នាក់ងារអនុវត្តច្បាប់បរទេសផ្សេងទៀត
- ព័ត៌មានសំងាត់ ឬមានវេទយិតភាពពាក់ព័ន្ធនឹងបញ្ហាផ្ទៃក្នុងអង្គភាព ជាពិសេសព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការរបស់រដ្ឋបាលគយ ព័ត៌មានសន្តិសុខ ឬព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេត និងការអនុវត្តច្បាប់ ។

**ប្រការ ២.-**

មន្ត្រីគយមិនត្រូវប្រើប្រាស់ព័ត៌មានសំងាត់ ឬមានវេទយិតភាព ឬមានលក្ខណៈពាណិជ្ជកម្ម សម្រាប់ប្រយោជន៍បុគ្គលផ្ទាល់ខ្លួន ឬសម្រាប់តម្រូវការដែលគ្មានការអនុញ្ញាតណាមួយឡើយ ។

មន្ត្រីគយមិនត្រូវយកចេញពីការិយាល័យគយនូវឯកសារ ឬព័ត៌មានផ្លូវការណាមួយ លើកលែងតែមានតម្រូវការសម្រាប់អនុវត្តការកិច្ចរបស់ខ្លួន និងមិនត្រូវផ្តល់ព័ត៌មាន ឬឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការរបស់រដ្ឋបាលគយទៅបុគ្គលដែលគ្មានការអនុញ្ញាត ។ មន្ត្រីគយដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃប្រកាសនេះនឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីគយ ឬ បទប្បញ្ញត្តិផ្សេងទៀតជាធរមាន ។

**ប្រការ ៣.-**

មន្ត្រីគយត្រូវបានអនុញ្ញាតឱ្យធ្វើទំនាក់ទំនង ឱ្យផ្តល់កិច្ចសហការ ឬអនុញ្ញាតឱ្យមានការត្រួតពិនិត្យព័ត៌មានរាប់បញ្ចូលទាំង សៀវភៅ បញ្ជី កំណត់ត្រា ឯកសារ ឬព័ត៌មានផ្សេងទៀតដែលទទួលបាននៅក្នុងការបំពេញភារកិច្ចរបស់ខ្លួនជូនទៅបុគ្គល ឬអង្គការនានាដូចខាងក្រោម ៖

- មន្ត្រីមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- បុគ្គលដែលមានសិទ្ធិស្របច្បាប់ទទួលព័ត៌មាន រាប់បញ្ចូលទាំងមន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីតុលាការ
- អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិរាប់បញ្ចូលទាំងនគបាល កងរាជអាវុធហត្ថ និងភ្នាក់ងារផ្សេងទៀតដែលបានចូលរួមក្នុងប្រតិបត្តិការអនុវត្តច្បាប់ជាមួយរដ្ឋបាលគយ
- មន្ត្រីមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានពន្ធដារ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បុគ្គលណាមួយដែលត្រូវបានទទួលការអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារ ឬតំណាងបុគ្គល ដែលបានផ្តល់ព័ត៌មាន សៀវភៅបញ្ជី កំណត់ត្រា និងឯកសារនានា រាប់បញ្ចូលទាំងភ្នាក់ងារគយ តំណាងស្របច្បាប់ និងនិយោជិកជាដើម

Downloaded from http://www.khmerlaws.com

- តំណាងរដ្ឋបាលគយ និងភ្នាក់ងារអនុវត្តច្បាប់បរទេសផ្សេងទៀត ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានកិច្ចព្រមព្រៀងផ្លូវការស្តីពីកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមក

- បុគ្គល និងអង្គការផ្សេងទៀតដែលមានការឯកភាពពីអគ្គនាយកគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៤ .-**

តាមការសម្រេចរបស់តុលាការមានសមត្ថកិច្ច មន្ត្រីគយអាចផ្តល់ជាបន្ទាល់ពាក់ព័ន្ធនឹងព័ត៌មានដែលទទួលបាន ក្រោមបញ្ញត្តិនៃច្បាប់ស្តីពីគយ និងរៀបចំនូវសៀវភៅ បញ្ជី កំណត់ត្រា និងឯកសារនានាជូនតុលាការ ។

**ប្រការ ៥ .-**

មន្ត្រីគយដែលបានបញ្ចេញព័ត៌មានតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរជូនអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ដោយមានរៀបរាប់ពីព័ត៌មានដែលបានផ្តល់ បុគ្គលដែលត្រូវបានផ្តល់ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

__ចម្លងជូន៖__
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

Downloaded from http://www.khmerlaws.com